# ក្របីឡើងក

ពាក្យ៨

ក្របីឡើងកហាក់វ៉ចង់ផល់ ខ្មៅមុខក្រពុលវល់ជាន់អ្នកស្រុក
ឆ្កែព្រូសឆ្ដែប្ដឹងទ្រហឹងអែអុក អាឡើងរត់បុកជាន់ស្លាប់មិនចៀស។

អាឡើងមាឧមាំព្រោះវាស៊ីឆ្អែត ស្នែងវែងត្រដែតអំណាចពេញពាស
អ្នកណាហ៊ានក្អកវាបកវាត់វាស ដាច់ឈាមរលាសជូនជាន់ដល់ក្សៀយ។

អាឡើងលេចផោមគេចោមអបអរ សើចសឹងបាកករទះសឹងបាកដៃ
សរសើរគ្រប់មាត់ថាក្រអូបក្រៃ អ្នកភ្លេចទះដៃត្រូវក្សៀយជីវ៉ា។

សត្វណាដុះស្នែងវែងចេញបន្តិច វាចោតថាល្បិចចង់វាយប្រហារ
វាថាខុសច្បាប់ខុសក្បួនដំរាល វាចាប់ទោសសារតាមចិត្តវាគិត។

កូនវាស្នែងខ្លីលែតឲ្យវែង អ្នកណាប្រជែងលែងរួចជីវិត
ខុសកូនអាឡើងគ្មានអំណាចសិទ្ធិ សត្វទាំងអស់ពិតគ្មានសិទ្ធិស្នែងវែង។

ញីអាឡើងវិញមិនចាញ់ចិត្តប្ដី ទៅណាគេខ្លីខ្លាចខ្លបជ្រោមជ្រែង
គេក្រាបសំពះជាជួរវែងៗ គ្មានអ្នកហានលែងសែងខ្លាចប៉ះដី។

ញីអាឡើងកាចអំណាចពេកពន់ គ្មានអ្នកថាធ្ងន់សើចដើរធ្វើហី
ទោះស្មាឈើក្ដៅក៏នៅប្រិមប្រិយ មិនហ៊ានហាស្ដីថាធ្ងន់សោះឡើយ។

ក្បួនដើរទៅណាមានគេបោសដី ឲ្យស្រស់ស្អាតថ្មីអ្វីៗក៏ល្ហើយ
ឃើញស្រស់គ្រប់ទីជីស្មោកន្តើយ បើគេទៅហើយត្រូវតែដកចេញ។

ចៅអាឡើងវិញទោះវាតូចខ្ចី    បើវាចង់ស្រីមិនបាច់ចាប់ដេញ
ស្រែកតែមួយមាត់ញីមករម៉ិញ    គ្មានអ្នកដើរចេញចូលដោយញញឹម។

ចៅទួតអាឡើងបើវារអផ្សុក    យកក្របីស្រុកមកដំរៀបផ្ទឹម
ទាញឈើមកគោះជំនួសភ្លេងឃឹម    ពួកនោះញញឹមសរសើរថាឆ្លាត។

ចំនែកចៅលាវាសាច់ឆ្ងាយហើយ    តែមិនអន់ឡើយទោះវាប្រែមាថ
ក៏គេគោរពដើរតាមយ៉ាងស្អាត    វាចេញឱវាទគេស្ដាប់គ្រប់គ្នា។

ពូជគេពូជល្អខ្លាំងតសន្ដាន    ល្បីសព្វទិសឋានគ្មានអ្នកនិន្ទា
ទោះខ្លួនត្រូវស្លាប់ដោយក្ដីវេទនា    នៅតែស្រែកលាថាស្លាប់ស្រួលណាស់។

ភ្នំពេញ ថ្ងៃទី ២៥ មករា ២០០៣
សូយ ឡូត